**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ : ៤៧៥៥ អយក.សក**

# សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រ ទៅសិក្សានៅប្រទេសសិង្ហបុរី សម្រាប់ឆ្នាំសិក្សា ២០១២-២០១៣

**យោង** : លិខិតស្ថានទូតសិង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ក្រសួងអប់រំ យុវជន និងកីឡា**

សូមជូនដំណឹងដល់និស្សិតឆ្នាំទី១ ឬឆ្នាំទី២ ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានានាក្នុងព្រះរាជាណាចក្រកម្ពុជាថា សម្រាប់ឆ្នាំសិក្សា២០១២-២០១៣ រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីបានផ្តល់អាហារូបករណ៍ដល់ប្រទេសជាសមាជិកសមាគមអាស៊ានក្នុងនោះមានព្រះរាជាណាចក្រកម្ពុជាផងដែរ ។ និស្សិតដែលទទួលបានអាហារូបករណ៍សិង្ហបុរី (Singapore Scholarship .SS ) នឹងត្រូវទៅសិក្សានៅសាកលវិទ្យាល័យបច្ចេក-វិទ្យាណាន់យ៉ាង( NTU ) ឬសាកលវិទ្យាល័យជាតិសិង្ហបុរី (NUS) ឬសាកលវិទ្យាល័យគ្រប់គ្រងសិង្ហបុរី ( SUM ) នៅប្រទេសសិង្ហបុរី ។

ភាគីមិត្តរ៉ាប់រងថ្លៃសិក្សា ផ្តល់ប្រាក់អាហារូបករណ៍ ការស្នាក់នៅ និងថ្លៃសំបុត្រយន្តហោះទៅ-មក ។

**I - មុខវិជ្ជាទៅសិក្សាមាន :**

-Arts and Social Sciences, Science, Economics, Civil Engineering......

**II - លក្ខខណ្ឌនៃការចុះឈ្មោះជាបេក្ខជន**

**បេក្ខជនទាំងពីរភេទត្រូវ :**

-មានសញ្ជាតិខ្មែរ

-ជានិស្សិតកំពុងសិក្សាឆ្នាំទី១ឬឆ្នាំទី២ នៅតាមគ្រឹះស្ថានឧត្តមសិក្សានានា

-ជានិស្សិតដែលរៀនពូកែ

-ចេះភាសាអង់គ្លេសជ្រៅជ្រះ

-មានសុខភាពល្អបរិបូណ៌ ទាំងកាយសម្បទា និងសតិបញ្ញា



អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៨៦ / ៤២៦ ៥៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

**III-កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅរហូតដល់ថ្ងៃទី **២៣** ខែ **ធ្នូ** ឆ្នាំ **២០១១** នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ អគារលេខ ២៣ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន (ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរាប្រហែល ៥០ ម៉ែត្រ) ។

**IV-កាលបរិច្ឆេទប្រឡង**

- សម័យប្រឡងថ្ងៃទី **២៩** ខែ **ធ្នូ** ឆ្នាំ **២០១១** ។ មណ្ឌលប្រឡង នឹងជម្រាបជូនពេលក្រោយ ។

**V-វិញ្ញាសាប្រឡងមាន :**

-គណិតវិទ្យា រយៈពេល ០១ ម៉ ៣០ នាទី

-ភាសាអង់គ្លេស រយៈពេល ០១ ម៉ ៣០ នាទី

**VI-សំណុំឯកសារដែលត្រូវបំពេញមាន :**

-ពាក្យសុំអាហារូបករណ៍ ០១ ច្បាប់ " មានគំរូ "

-ជីវប្រវត្តិសង្ខេប ០១ ច្បាប់ " មានគំរូ "

- រូបថតពណ៌ ៤ គុណ ៦ ០២ សន្លឹក (រូបថតថ្មី ថតចំពីមុខ គ្មានពាក់វ៉ែនតា)

-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិច្បាប់ថតចម្លង ០១ច្បាប់ (ភ្ជាប់មកជាមួយច្បាប់ដើម) ដើម្បីផ្ទៀងផ្ទាត់។

-សេចក្តីបញ្ជាក់ពីប្រធានគ្រឹះស្ថានដែលសាមីជនកំពុងសិក្សា

ផ្អែកលើលទ្ធផលប្រឡង ក្រសួងនឹងជ្រើសរើសបេក្ខជនចំនួន**៣០**នាក់បញ្ជូនទៅភាគីមិត្តធ្វើតេស្ត និងសម្ភាសន៍បន្តទៀត ដើម្បីជ្រើសរើសយកតាមចំនួនកំណត់ជាក់ស្តែង ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១

**ត.ប រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អគ្គនាយករង**

**សៀ-សុជាតា**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមហាផ្ទៃ
- ស្ថានទូតសាធារណរដ្ឋសិង្ហបុរី នៅភ្នំពេញ

" *ដើម្បីជូនជ្រាបជាព័ត៌មាន* "

- គ្រប់ក្រសួង -រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា

" *ដើម្បីជួយផ្សព្វផ្សាយដល់បេក្ខជន* "

- កាលប្បវត្តិ-ឯកសារ ន.ទវអ